# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ២០១៦

## ជប៉ុនផ្តល់ថវិកាសរុបចំនួន ៣០៥,៣១៤ ដុល្លារអាមេរិក សម្រាប់ការអនុវត្តគម្រោងចំនួនបួន

ក្រោមគ្រោងការណ៍នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុន ជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (ជំនួយគូសាណូណេ) រដ្ឋាភិបាលជប៉ុន បានយល់ព្រមផ្តល់ថវិកាសរុបចំនួន **៣០៥,៣១៤ ដុល្លារអាមេរិក** ដល់អង្គភាពទទួលជំនួយចំនួនបួន។ កិច្ចសន្យាផ្តល់ជំនួយ ត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ ដោយឯកឧត្តម ហ៊ីដេហ៊ីសា ហូរីណូអ៊ុជិ ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងអ្នកតំណាងស្ថាប័នទទួលជំនួយទាំងបួនសម្រាប់គម្រោងដូចតទៅៈ

**១. <u>គម្រោងសាងសង់អគារសិក្សាមួយខ្នង នៅសាលាបឋមសិក្សាឈើទាលជ្រុំ ក្នុងស្រុកវាលវែង ខេត្តពោធិ៍សាត់ (ថវិកាចំនួន ៥៨,៨០០ ដុល្លារអាមេរិក)</u>**

<u>អង្គភាពទទួលជំនួយៈ អង្គការកម្ពុជាដើម្បីកុមារ និងការអភិវឌ្ឍន៍</u>

គម្រោងនេះ នឹងសាងសង់អគារសិក្សាមួយខ្នងដែលបំពាក់ទៅដោយបរិក្ខារសិក្សា និងបង្គន់អនាម័យមួយខ្នង នៅសាលាបឋមសិក្សាឈើទាលជ្រុំ ខេត្តពោធិ៍សាត់។ ជាមួយនឹងគម្រោងនេះ សិស្សានុសិស្សប្រមាណជា ២២០នាក់ នឹងអាចសិក្សានៅក្នុងបរិស្ថានអប់រំប្រកបដោយផាសុខភាពជាងមុន ។

**២. <u>គម្រោងសាងសង់អគារសិក្សាមួយខ្នង នៅសាលាបឋមសិក្សាបឹងស្នួល ក្នុងស្រុកបវេល ខេត្តបាត់ដំបង (ថវិកាចំនួន ៨១,៨១៨ ដុល្លារអាមេរិក)</u>**

<u>អង្គភាពទទួលជំនួយៈ មន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង</u>

គម្រោងនេះ នឹងសាងសង់អគារសិក្សាមួយខ្នង ដែលបំពាក់ទៅដោយបរិក្ខារសិក្សានៅបឋមសិក្សាបឹងស្នួល ក្នុងខេត្តបាត់ដំបង។ គម្រោងនេះត្រូវបានរំពឹងថា សិស្សានុសិស្សប្រមាណជា ២៣០នាក់ នឹងអាចសិក្សានៅក្នុងថ្នាក់រៀនថ្មីប្រកបដោយផាសុខភាពជាងមុន ។

**៣. <u>គម្រោងសាងសង់អគារសិក្សាមួយខ្នង នៅសាលាបឋមសិក្សាឃ្លាំង ក្នុងស្រុកបាភ្នំ ខេត្តព្រៃវែង (ថវិកាចំនួន ៨២,៣៥៥ ដុល្លារអាមេរិក)</u>**

<u>អង្គភាពទទួលជំនួយៈ មន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រៃវែង</u>

គម្រោងនេះ នឹងសាងសង់អគារសិក្សាមួយខ្នង ដែលបំពាក់ទៅដោយបរិក្ខារសិក្សា និងបង្គន់អនាម័យ នៅសាលាបឋមសិក្សាឃ្លាំង ក្នុងខេត្តព្រៃវែង។ គម្រោងនេះត្រូវបានរំពឹងថា សិស្សានុសិស្សប្រមាណជា ៦១០នាក់ នឹងអាចធ្វើការសិក្សានៅក្នុង

ថ្នាក់រៀនថ្មីប្រកបទៅដោយផាសុខភាពជាងមុន។

**៤. គម្រោងសាងសង់អគារសម្ភព និងរោគស្ត្រី នៅមន្ទីរពេទ្យបង្អែកត្រពាំងក្រឡឹង ក្នុងខេត្តកំពង់ស្ពឺ (ថវិកាចំនួន ៨២,៣៤១ ដុល្លារអាមេរិក)**

អង្គភាពទទួលជំនួយ៖ ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិភ្នំស្រួច ខេត្តកំពង់ស្ពឺ

គម្រោងនេះ នឹងធ្វើការសាងសង់នូវអគារសម្ភព និងរោគស្ត្រីមួយខ្នង ដើម្បីផ្តល់សេវាសុខភាពអោយកាន់តែប្រសើរឡើងនៅក្នុងមន្ទីរពេទ្យបង្អែកត្រពាំងក្រឡឹង ក្នុងខេត្តកំពង់ស្ពឺ។ តាមរយៈគម្រោងនេះ អ្នកជម្ងឺប្រមាណជា ៧,២០០នាក់ នឹងអាចទទួលបាននូវសេវាសុខភាព កាន់តែល្អប្រសើរជាងមុន។

*ជំនួយឥតសំណងគូសាណូណិរបស់ជប៉ុន* បានចាប់ផ្តើមនៅប្រទេសកម្ពុជានៅឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍ និងស្តាបនាប្រទេសឡើងវិញនៅតាមកម្រិតមូលដ្ឋាន។ គម្រោងជំនួយនេះ មានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និងភាពអកុសល ដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជីវិត និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង៥៥លានដុល្លារអាមេរិកដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាលដើម្បីអនុវត្តគម្រោងគូសាណូណិចំនួន៥៥៨ គម្រោងនៅទូទាំងប្រទេសកម្ពុជា។

---

*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*
*ទូរស័ព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០*
*អ៊ីមែល: eco.jpn@pp.mofa.go.jp*
*គេហទំព័រ: http://www.kh.emb-japan.go.jp*